# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ០៦ រប-៩៧

## <u>សារាចរ</u>

### <u>ជូនចំពោះ</u>

### លោកចៅក្រមទាំងអស់ នៃព្រះរាជាណាចក្រកម្ពុជា

<u>**សូមជ្រាប។**</u>

<u>**កម្មវត្ថុ:**</u> រក្សាទុក និងបដិសេធសារាចរលេខ០៥ រ.ប-៩៧ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៩៧ របស់ក្រសួងយុត្តិធម៌ ។

ក្រោយពីបានពិនិត្យយ៉ាងល្អិតល្អន់ នូវសារាចរលេខ ០៥ រ. ប.៩៧ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៩៧ ហើយដែលក្រសួងបានផ្ញើទៅអោយលោកចៅក្រមទាំងអស់នៃព្រះរាជាណាចក្រកម្ពុជានោះមក ។

ក្នុងឋានៈខ្ញុំជាអ្នកទទួលខុសត្រូវក្នុងក្រសួងយុត្តិធម៌ ខ្ញុំសូមធ្វើការណែនាំដូចខាងក្រោម ៖

ដោយរង់ចាំការពិនិត្យ និង សម្រេចយកជាបានការតាមផ្លូវច្បាប់នូវសារាចរលេខ០៥ រ.ប.៩៧ នេះជាពិសេសរង់ចាំយោបល់ដ៏ខ្ពង់ខ្ពស់របស់សម្តេចនាយករដ្ឋមន្ត្រីទាំងពីរ ។

ចៅក្រមទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា ៖

-មិនត្រូវសម្រេចសេចក្តី ឬ ចេញដីកាណាមួយជាផ្លូវតុលាការ ដោយយោងតាមសារាចរលេខ០៥ រ.ប-៩៧ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៩៧ នេះទេ ។

សេចក្តីសម្រេច ឬការចេញដីការអ្វីមួយ ដែលបានចេញរួចមកហើយ ហើយដែលបានយោងលើសារាចរលេខ០៥ រ.ប.៩៧ នេះត្រូវទុកជាមោឃៈជាដាច់ខាត ។

តុលាការយើងសព្វថ្ងៃមានកេរ្តិ៍ឈ្មោះមិនល្អជាងពេលណាៗទាំងអស់ ខ្ញុំសូមលោកចៅក្រមទាំងអស់យកចិត្តទុកដាក់គោរពអនុវត្តយកច្បាប់ជាធរមានជាធំ ឯករាជ្យ បម្រើផលប្រយោជន៍ យុត្តិធម៌ដល់ប្រជាពលរដ្ឋយើង ។

ធ្វើនៅភ្នំពេញ ថ្ងៃទី០៨ ខែឧសភា ឆ្នាំ១៩៩៧

**រដ្ឋលេខាធិការ**

**អ៊ុក វីធុន**